សលាកប័ត្រព័ត៌មាន៖ កម្រងឯកសារស្តីពីស្ថាប័ន ៖ ក្រុមប្រឹក្សាឃុំ/សង្កាត់
ស្ថាប័ន៖ ក្រុមប្រឹក្សាឃុំ/សង្កាត់
ទិដ្ឋភាពរួម៖ ការធ្វើវិមជ្ឈការនៃរដ្ឋបាលមូលដ្ឋាន ដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលត្រូវបានជ្រើសតាំងតាមរយៈការបោះឆ្នោតដោយសេរី ជាទ្រឹស្តីគឺជាជំហានមួយគួរឲ្យស្វាគមន៍ ចំពោះទិដ្ឋភាពប្រជាធិបតេយ្យនៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”)។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការរារាំងមិនឲ្យបេក្ខជនឯករាជ្យ ចូលរួមក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ គឺហាក់ដូចជាផ្ទុយទៅនឹងគោលការណ៍ស្នូលនៃប្រព័ន្ធវិមជ្ឈការ ដែលជាប្រព័ន្ធមួយអាចនាំលទ្ធិប្រជាធិបតេយ្យឲ្យចូលទៅកាន់តែជិតប្រជាពលរដ្ឋ តាមរយៈការបង្កើនកម្រិតភាពជាអ្នកតំណាងនៅថ្នាក់មូលដ្ឋាន។ តាមពិត នាពេលបច្ចុប្បន្ននេះ ដំណើរការនយោបាយនៅថ្នាក់មូលដ្ឋាន គឺជាបង្កឲ្យមានការត្រួតត្រានយោបាយលើរដ្ឋបាលនៅគ្រប់កម្រិត។

សេចក្តីផ្តើម

ដោយសារការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ នឹងត្រូវប្រព្រឹត្តិទៅនៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០១២ សលាកប័ត្រនេះផ្តល់នូវទិដ្ឋភាពដ៏សមស្របមួយ ដែលទាក់ទងនឹងក្រុមប្រឹក្សាឃុំ/សង្កាត់ និងនីតិវិធីបោះឆ្នោត ដោយគូសបញ្ជាក់អំពីការគ្រប់គ្រងទាំងស្រុងដោយនយោបាយបង្កើតឡើងដោយគណបក្សកាន់អំណាច និងផ្តល់ជាអនុសាសន៍មួយចំនួន សម្រាប់កំណែទម្រង់ដំណើរការនយោបាយ។ សលាកប័ត្រនេះត្រូវបានតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (“ម.ស.ម.ក”) ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិប្បតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

សរគារ

យោងតាមប្រវត្តិសាស្ត្ររបស់ខ្លួន ប្រទេសកម្ពុជាកន្លងមកមានប្រព័ន្ធរដ្ឋបាលគ្រប់គ្រងតាមបែបមជ្ឈការដ៏ស៊ីជម្រៅ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០០១ នៅពេលច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ (“ច្បាប់ឃុំ/សង្កាត់”) ត្រូវបានអនុម័ត រាជរដ្ឋាភិបាលកម្ពុជា (“រដ្ឋាភិបាល”) បានទទួលស្គាល់អំពីសារៈសំខាន់នៃប្រព័ន្ធវិមជ្ឈការ ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ លើសពីនេះទៀត វាក្យស័ព្ទ (“វិមជ្ឈការ និងវិសហមជ្ឈការ”) ជាធាតុដ៏សំខាន់ដែលបានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលឆ្នាំ២០០៤ ចំពោះទស្សនៈវិស័យនៃការអភិវឌ្ឍន៍រយៈពេលយូរអង្វែង និងភាពរីកចម្រើន។ ប្រព័ន្ធវិសហមជ្ឈការគឺជានីតិវិធីមួយនៃការបែងចែងអំណាចក្នុងការធ្វើសេចក្តីសម្រេច និងការគ្រប់គ្រងទៅឲ្យថ្នាក់មូលដ្ឋានដែលនៅជិតប្រជាពលរដ្ឋ។ ការបោះឆ្នោតជ្រើសរើសអ្នកតំណាងនៅថ្នាក់មូលដ្ឋាន មានគុណសម្បត្តិពីរគឺ៖ (១) ប្រជាពលរដ្ឋមានអារម្មណ៍ថាខ្លួនបានចូលរួមយ៉ាងជិតដល់នៅក្នុងដំណើរការប្រជាធិបតេយ្យ និង(២) ការសម្រេចចិត្តនៅថ្នាក់មូលដ្ឋាន ជាទូទៅគឺមានលក្ខណៈសមស្រប និងឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍នីមួយៗប្រសើរជាងការសម្រេចចិត្តធ្វើឡើងដោយរដ្ឋបាលថ្នាក់កណ្តាល។

ក្រុមប្រឹក្សាឃុំ/សង្កាត់ – រចនាសម្ព័ន្ធ និងការប្រព្រឹត្តិទៅ

យោងតាមមាត្រា១៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឃុំ/សង្កាត់គឺជារដ្ឋបាលគ្រប់គ្រងទាបជាងគេបង្អស់ ដោយក្នុងនោះមានឃុំ/សង្កាត់ចំនួន ១ ៦២១ នៅទូទាំងប្រទេសកម្ពុជា។ ក្រុមប្រឹក្សាឃុំ/សង្កាត់នីមួយៗមានសមាជិកពី៥ ទៅ១១រូប ផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន (មាត្រា១២ នៃច្បាប់ឃុំ/សង្កាត់)។ ក្រុមប្រឹក្សាឃុំ/សង្កាត់នីមួយៗមានប្រធានម្នាក់ ដែលជាប្រធានក្រុមប្រឹក្សាឃុំ/សង្កាត់ និងត្រូវជំនួយដោយជំទប់ទី១/ចៅសង្កាត់រងទី១ម្នាក់ និងជំទប់ទី២/ចៅសង្កាត់រងទី២ម្នាក់ (មាត្រា៣៣) ហើយក្រុមប្រឹក្សាឃុំ/សង្កាត់ត្រូវធ្វើការជួបប្រជុំយ៉ាងហោចណាស់មួយខែម្តង (មាត្រា២១)។ គម្រោងផែនការអភិវឌ្ឍន៍ គម្រោងថវិកា ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធមូលដ្ឋាន និងកំរៃសេវាផ្សេងៗ ។ល។ នៅក្នុងឃុំ/សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ដោយសំឡេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព (មាត្រា២២)។ ក្រុមប្រឹក្សាឃុំ/សង្កាត់មានតួនាទីពីរគឺ (មាត្រា៤២)៖ (១) តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ/សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ/សង្កាត់របស់ខ្លួន និង(២) តួនាទីជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ ដែលធ្វើឲ្យមានការចោទជាសំនួរឡើងទាក់ទងនឹងថាតើក្រុមប្រឹក្សាឃុំ/សង្កាត់តំណាងឲ្យនរណាពិតប្រាកដ (រាស្ត្រ ឬក៏រដ្ឋ) ចំណែកបញ្ហាមួយទៀតគឺអត្ថិភាពនៃទំនាស់ផលប្រយោជន៍។ ក្រុមប្រឹក្សាឃុំ/សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ (មាត្រា៤៨) ហើយមានតួនាទី/កាតព្វកិច្ចបន្ទាប់បន្សំជាច្រើនទៀតនៅក្នុងការប្រព្រឹត្តិទៅរបស់ខ្លួន។

ការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់

ប្រជាពលរដ្ឋនៃឃុំ/សង្កាត់នីមួយៗ បោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់របស់ខ្លួនដោយផ្ទាល់ ហើយអាណត្តិរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់មានរយៈពេល៥ឆ្នាំ (មាត្រា ១០ និង១១)។ ការបោះឆ្នោតអាចប្រព្រឹត្តិទៅបានតែក្នុងឃុំ/សង្កាត់ណាមានគណបក្សនយោបាយចុះឈ្មោះឈរជាតំណាងឲ្យគេបោះឆ្នោតលើសពីមួយ និងផ្អែកលើមូលដ្ឋានតំណាងដោយសមាមាត្រ ដោយគណបក្សនយោបាយដែលបានចុះបញ្ជីនីមួយៗត្រូវធ្វើបញ្ជីបក្ខជនឈរឈ្មោះតាមលេខរៀង។ ចំនួនអាសនៈក្រុមប្រឹក្សាឃុំ/សង្កាត់គឺត្រូវធ្វើការបែងចែកទៅតាមចំនួនសន្លឹកឆ្នោត

ដែលគណបក្សនីមួយៗទទួលបាន។ អនុលោមតាមច្បាប់ស្តីពីគណបក្សនយោបាយ គ្រប់គណបក្សនយោបាយទាំងអស់ត្រូវធ្វើការចុះបញ្ជីនៅឯក្រសួងមហាផ្ទៃ (មាត្រា១៨) ហើយត្រូវតែមានសមាជិកយ៉ាងហោចណាស់ចំនួន ៥០០០រូប មកពីខេត្ត/ក្រុងមួយចំនួន (មាត្រា១៩)។ រហូតមកដល់ពេលបច្ចុប្បន្ននេះ កម្ពុជាបានធ្វើការបោះឆ្នោតឃុំ/សង្កាត់បានចំនួនពីរលើករួចមកហើយ លើកទីមួយត្រូវបានធ្វើឡើងនៅឆ្នាំ២០០២ និងលើកទីពីរនៅឆ្នាំ២០០៧។ អាសនៈសរុបចំនួន១១ ៣៥៣អាសនៈត្រូវបានធ្វើការប្រកួតប្រជែងក្នុងការបោះឆ្នោតឃុំ/សង្កាត់ឆ្នាំ២០០៧ ដោយក្នុងនោះគណបក្សប្រជាជនកម្ពុជា (“ប្រ.ជ”) ទទួលបាន ៧ ៩៩៣អាសនៈ គណបក្ស សម រង្ស៊ី ២ ៦៦០អាសនៈ គណបក្សហ៊្វុនស៊ិនប៉ិច២៧៤អាសនៈ និងគណបក្ស នរោត្តមរណរិទ្ធិ ៤២៥អាសនៈ។ គណបក្សតូចៗគឺមានភាពជាតំណាងតិចតួចបើប្រៀបទៅនឹងការបែងចែកសន្លឹកឆ្នោតដែលបោះដោយប្រជាពលរដ្ឋ នៅខណៈដែលគណបក្សប្រជាជនឈ្នះ ៧០ភាគរយនៃចំនួនអាសនៈសរុប បើទោះណាជាខ្លួនតំណាងឲ្យត្រឹមតែ៦០ភាគរយនៃចំនួនសន្លឹកឆ្នោតប្រជាពលរដ្ឋ គណបក្សនរោត្តមរណរិទ្ធិទទួលបានត្រឹមតែ៣,៧ភាគរយប៉ុណ្ណោះ បើទោះណាជាខ្លួនបានទទួលការគាំទ្រ៨ភាគរយពីអ្នកបោះឆ្នោតសរុបក៏ដោយ។

ការគ្រប់គ្រងទាំងស្រុង

ប្រសិទ្ធិភាពនៃការបោះឆ្នោតទាំងនេះគឺស្ថិតនៅឆ្ងាយពីថាវភាពនៃឃុំ/សង្កាត់ ដោយសារតែគណបក្សកាន់អំណាចអាចគ្រប់គ្រងក្រុមប្រឹក្សាឃុំ/សង្កាត់តាមរយៈលក្ខខណ្ឌតម្រូវមួយដែលថាមានតែគណបក្សនយោបាយដែលត្រូវបានបង្កើតតែប៉ុណ្ណោះ ដែលអាចតែងតាំងបេក្ខជនឲ្យឈរឈ្មោះ ហើយដោយសារក្រោយមកគឺក្រុមប្រឹក្សាឃុំ/សង្កាត់ជាអ្នកតែងតាំងប្រធានភូមិចំនួន១៣ ០០០នាក់ ដូច្នេះការគ្រប់គ្រងគឺត្រូវបានពន្លាតរហូតដល់ថ្នាក់ក្រោមបំផុត។ លើសពីនេះទៀត ដោយសារតែអាជ្ញាធរមូលដ្ឋាន អាចគ្រប់គ្រងលើការចុះបញ្ជីអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតថ្នាក់ជាតិ និងឃ្លាំមើលយ៉ាងប្រុងប្រយ័ត្នទៅលើយុទ្ធនាការឃោសនាបោះឆ្នោត ការគ្រប់គ្រងនេះក៏ប្រែក្លាយទៅជាការផ្សារភ្ជាប់ទៅនឹងការក្តាប់ក្តាប់អំណាចរបស់គណបក្សកាន់អំណាចនៅថ្នាក់ជាតិផងដែរ។ បន្ថែមលើការពិតជាក់ស្តែងនេះ ការគ្រប់គ្រងដូចគ្នានេះក៏ត្រូវបានយកទៅអនុវត្តនៅថ្នាក់ស្រុក និងខេត្ត ដោយធ្វើការភ្ជាប់គ្នារវាងរដ្ឋបាលថ្នាក់មូលដ្ឋាន និងរដ្ឋបាលថ្នាក់ជាតិ ព្រោះថាសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់គឺជាអ្នកបោះឆ្នោតអាជ្ញាធរស្រុក និងខេត្ត ដូច្នេះហើយទើបការគ្រប់គ្រងនយោបាយ របស់គណបក្សកាន់អំណាចគឺមាននៅគ្រប់ទីកន្លែង។ លើសពីនេះទៀត គណៈកម្មាធិការរៀបចំការបោះឆ្នោតឃុំ/សង្កាត់ គឺត្រូវបានជ្រើសរើសដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយជាទូទៅគឺពោរពេញទៅដោយសមាជិកដែលជាមនុស្សគាំទ្ររដ្ឋភិបាល។ ចុងក្រោយក្រុមប្រឹក្សាឃុំ/សង្កាត់ ជ្រើសរើសអាសនៈភាគច្រើនមហិមារនៅក្នុងសភាជាន់ខ្ពស់ នៃប្រព័ន្ធសភាទ្វិកនិយម ដែលត្រូវបានគេស្គាល់ថាព្រឹទ្ធិសភា ហេតុដូច្នេះហើយទើបប្រព័ន្ធដែលលំអៀង និងគ្មានសមាមាត្រនេះ ជះឥទ្ធិពលដោយផ្ទាល់ទៅលើសមាសភាពនៃអង្គនីតិបញ្ញត្តិ។ ដូច្នេះ ការគ្រប់គ្រងនយោបាយទាំងស្រុងដោយគណបក្សកាន់អំណាច គឺសម្រេចទៅបានតាមរយៈការប្រមូលផ្តុំផ្តាច់មុខនូវរាល់ចរន្ត និងហេដ្ឋារចនាសម្ព័ន្ធនយោបាយរបស់រដ្ឋាភិបាលនៅគ្រប់កម្រិត។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការធ្វើវិមជ្ឈការអភិបាលកិច្ច ទៅក្រុមប្រឹក្សាឃុំ/សង្កាត់ដែលត្រូវបានបោះឆ្នោតប្រកបដោយលក្ខណៈប្រជាធិបតេយ្យ នៅក្នុងទ្រឹស្តីគឺជាជំហានដ៏វិជ្ជមានមួយសម្រាប់លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការរារាំងមិនឲ្យបេក្ខជនឯករាជ្យ ចូលរួមក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ/សង្កាត់ គឺហាក់ដូចជាផ្ទុយទៅនឹងគោលការណ៍ស្នូលនៃប្រព័ន្ធវិមជ្ឈការ ដែលជាប្រព័ន្ធមួយអាចនាំលទ្ធិប្រជាធិបតេយ្យឲ្យចូលទៅកាន់តែជិតប្រជាពលរដ្ឋ តាមរយៈការបង្កើនកម្រិតភាពជាអ្នកតំណាងនៅថ្នាក់មូលដ្ឋាន។ ម.ស.ម.ក សូមស្នើជាអនុសាសន៍ដើម្បីកំណែទម្រង់ ដូចខាងក្រោម៖

- បេក្ខជនក្រុមប្រឹក្សាឃុំ/សង្កាត់ គួរតែឯករាជ្យទាំងស្រុង និងមិនជាប់ទាក់ទងជាចំហរទៅនឹងគណបក្សនយោបាយណាមួយឡើយ
- គណៈកម្មាធិការរៀបចំការបោះឆ្នោតឃុំ/សង្កាត់គួរត្រូវបានបំពេញដោយអ្នកជំនាញផ្នែកបោះឆ្នោតដែលឯករាជ្យ និងទៀងត្រង់ដើម្បីធានាឲ្យមានដំណើរការបោះឆ្នោតប្រកបដោយភាពសុក្រិត្យ
- ប្រធានភូមិ និងអាជ្ញាធរស្រុក/ខេត្ត គួរត្រូវបានបោះឆ្នោតដោយប្រជាពលរដ្ឋផ្ទាល់
- ច្បាប់ជាប់ពាក់ព័ន្ធនានា រួមមានដូចជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ និងច្បាប់ស្តីពីគណបក្សនយោបាយ គួរត្រូវបានធ្វើវិសោធនកម្មដើម្បីសម្រេចរាល់អនុសាសន៍ទាំងអស់នេះ។

សម្រាប់ព័ត៌មានបន្ថែមសុំទាក់ទង លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទលេខ (៨៥៥) ១២ ៤០ ៤០ ៥១ ឬតាមរយៈអ៊ីមែល ouvirak@cchrcambodia.org
និង លោករ៉ូប៊ឺត ហ្វីន តាមរយៈទូរស័ព្ទលេខ (៨៥៥) ៧៨ ៨០ ៩៩ ៦០ ឬតាមរយៈអ៊ីមែល robert.finch@cchrcambodia.org ។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights